Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## រោគកញ្ជ្រឹល [MEASLES]

### តើរោគកញ្ជ្រឹលគឺជាអ្វី?

រោគកញ្ជ្រឹលជាជម្ងឺដ៏ងាយស្រួលឆ្លង បង្កដោយវីរុសមួយ ។ វីរុសនោះហៅថា រូបីយ៉ូឡា ។

### តើរោគកញ្ជ្រឹលត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?

រោគកញ្ជ្រឹលអាចឆ្លងបានតាមរយៈរបៀបទាំងឡាយខាងក្រោមនេះ:

- តាមដំណក់តូចល្អិត មកពីការក្អក ឬកណ្តាស់ ។
- តាមការប៉ះពាល់ដំណក់ទឹកតូចល្អិតមកពីច្រមុះ និងបំពង់ក ។

### តើអាចមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាអាចមានរួមទាំង:

- កន្ទួលដែលចាប់ផ្តើមនៅលើមុខ និងក ហើយរាលដាល
- ក្តៅខ្លួនយ៉ាងខ្លាំង
- ហៀរសំបោរ
- ភ្នែកក្រហម ស្រក់ទឹកភ្នែកRed watery eyes
- ក្អក

### តើរោគកញ្ជ្រឹលត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

ដោយការពិនិត្យពេទ្យ ហើយនិងការពិសោធន៏ ។

### តើរោគកញ្ជ្រឹលត្រូវបានព្យាបាលយ៉ាងដូចម្តេច?

- គ្មានវិធីព្យាបាលពិតប្រាកដទេ ។
- កុមារមានរោគកញ្ជ្រឹល មិនត្រូវចូលសាលារៀនរយៈពេលបួនថ្ងៃក្រោយពីចាប់ផ្តើមកើតកន្ទួល ហើយនិងកំដៅខ្លួន និងរោគសញ្ញាដទៃទៀតជាអស់ហើយ ។

### តើអាចបង្ការរោគកញ្ជ្រឹលបានយ៉ាងដូចម្តេច?

- រោគកញ្ជ្រឹលអាចបង្ការបានដោយសារថ្នាំបង្ការរោគកញ្ជ្រឹល ។ ថ្នាំបង្ការត្រូវបានចាក់ជាផ្នែកមួយនៃថ្នាំបង្ការ MMR ដែលគេចាក់ឱ្យកុមារម្តងនៅត្រឹមអាយុ 12-15 ខែ ហើយម្តងទៀតនៅអាយុ 4 ទៅ 6 ឆ្នាំ ។

### សម្រាប់ព័តិមានបន្ថែមអំពីរោគកញ្ជ្រឹល:

Ottawa County Health Department
www.miOttawa.org
Center for Disease Control and Prevention
www.cdc.gov/nip/diseases/measles/default.htm
ទូរស័ព្ទ: (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វ៉ិបសាយ: www.miOttawa.org